ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកោះកុង

សំណុំរឿងព្រហ្មទណ្ឌលេខ១១៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦

សាលក្រម
លេខ ៦៥ "ឃ"
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ ដោយមានសមាសភាពដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូខេត្តកោះកុង

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ១១៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ ដែលរួមមានជនជាប់ចោទៈ

១/.ឈ្មោះ [redacted] ភេទស្រី អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កាត់ លេខ៥ ខេត្តព្រះសីហនុ ទីលំនៅបច្ចុប្បន្ន នៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្ត កោះកុង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] ស) ប្តីឈ្មោះ [redacted] មានកូន០៣ នាក់ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

២/.ឈ្មោះ [redacted] ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរយោធា មានទីកន្លែងកំណើតនៅភូមិកន្ទោរ ឃុំកន្ទោរ ឃុំកន្ទោរ ស្រុកកំពង់ត្រាច ខេត្តកំពត មានទីលំនៅបច្ចុប្បន្នភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ គំរាមកំហែង ប្រព្រឹត្តនៅចំណុច ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២១.០៧.២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ១២១ ត.៧/១៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកោះកុង។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ០៨ អ.យ/១៨ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

- បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ១២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងខេត្តកោះកុង។



Scanned by CamScanner

## អង្គហេតុមានដូចនេះ

កាលពីថ្ងៃទី២១.០៧.២០១៦ វេលាម៉ោង១៥ និង៣០នាទី ឈ្មោះ[redacted] បានយកកូនស្រីរបស់ខ្លួនឈ្មោះ[redacted] នៅផ្ទះឈ្មោះ[redacted] និងប្រពន្ធឈ្មោះ[redacted] ត្រូវជាបងថ្លៃ ស្ថិតក្នុងភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ជូនកូនដើរលេង ពេលទៅដល់ឈ្មោះ[redacted] បានចេញមកប្រាប់និយាយថា អញមិនឲ្យកូនទេហែងវិញទេ ចាប់ពីពេលនេះទៅ ព្រោះហែងបង្កបញ្ហារហូតពេលបានជួបកូនម្ដងៗ រួចឈ្មោះ[redacted] បានចេញមកតាមក្រោយហើយនិយាយថា ហែងទៅឲ្យឆាប់ រាញ់បាញ់ហែងចោលឥឡូវ ហើយឈ្មោះ[redacted] បានទូរស័ព្ទទៅកូនប្រុសឈ្មោះ[redacted]ឲ្យមកវាយឈ្មោះ[redacted]ឲ្យឆាប់ ពេលលឺដូច្នេះឈ្មោះ[redacted]ក៏ជិះកង់មកដាក់ពាក្យបណ្ដឹងតែម្ដង ។

- តុលាការប្រកាសបើកសវនាការ
- តុលាការប្រកាសអំពីសមាសភាពជំនុំជម្រះ
- តុលាការសួរអំពីអត្តសញ្ញាណជនជាប់ចោទ
- តុលាការប្រាប់សិទ្ធិដល់ជនជាប់ចោទ
- តុលាការប្រាប់សិទ្ធិដល់សាក្សី
- ជនជាប់ចោទមិនជំទាស់ និងសមាសភាពជំនុំជម្រះទេ

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]បានអវត្តមាន ។ ក្រឡាបញ្ជីបានអានអំណានកំណើតហេតុនៅក្នុងតំណាក់អយ្យការ។ជនជាប់ចោទបានឆ្លើយថា៖ កាលពីថ្ងៃមិនចាំ ខែកក្កដា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល១៥ និង៣០នាទីរសៀល ខ្ញុំចេញពីបន្ទប់ទឹកក្នុងផ្ទះស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឃើញប្រពន្ធរបស់ខ្ញុំឈ្មោះ[redacted] ប៉ុណ្ណារី បានឈរនៅមុខផ្ទះកំពុងហាមឈ្មោះ[redacted]ត្រូវជាប្អូនថ្លៃ មិនឲ្យចូលក្នុងផ្ទះរបស់ខ្ញុំបាទ ពេលនោះខ្ញុំក៏បានចេញទៅដេញឈ្មោះ[redacted]មិនឲ្យចូលមកក្នុងផ្ទះរបស់ខ្ញុំបាទទេ ដោយឈ្មោះ[redacted]មានស្ថានភាពស្រវឹងជោគ ដើរគ្រេតគ្រូត ខ្ញុំបាននិយាយថា អញមិនឲ្យអែងចូលផ្ទះអញទេ បើឯងស្រវឹងជោកចឹង ពេលនោះក្មួយស្រីរបស់ខ្ញុំ ឈ្មោះ[redacted]បានដើរមកជួបឈ្មោះ[redacted]យក្លែត ដោយឈ្មោះ[redacted]បានឲ្យអ្វីទៅកូនគេនោះខ្ញុំក៏មិនបានដឹងទេ ពេលដែលជួបកូនគេហើយឈ្មោះ [redacted]បានបណ្ដើរកង់ចេញពីផ្ទះរបស់ខ្ញុំតែម្ដងទៅ ។ ខ្ញុំមិនបានគំរាមឈ្មោះ[redacted]ទេគឺគ្រាន់តែមិនឲ្យឈ្មោះ[redacted]ជាន់ដីផ្ទះខ្ញុំ ។ ប្រពន្ធខ្ញុំឈ្មោះ [redacted]មិនបានជេរប្រមាថ ឬគំរាមកំហែង អ្វីនោះទេ ។ ខ្ញុំមិនបានរកបាញ់ឈ្មោះ[redacted]អ្វីនោះទេ ។

-ជនជាប់ចោទឈ្មោះ[redacted]បានអវត្តមាន ។ ក្រឡាបញ្ជីបានអានអំណានកំណើតហេតុនៅក្នុងតំណាក់អយ្យការ ។ ជនជាប់ចោទបានឆ្លើយថា៖ កាលពីថ្ងៃមិនចាំខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១៥ និង០០នាទី ខ្ញុំនិងប្ដី ឈ្មោះ[redacted]បាននៅក្នុងផ្ទះស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ស្រាប់តែឈ្មោះ[redacted] មកយកកូនរបស់គេ ឈ្មោះ[redacted]ដែលមានម្ដាយឈ្មោះ[redacted]ដែលបានជាកូនក្មេងលែងលះគ្នាជាមួយឈ្មោះ[redacted]តែមិនទាន់ចេញសាលក្រម ហើយពួកគេស្នាក់នៅផ្ទះជាមួយនាងខ្ញុំ និងប្ដី ។ ពេលនោះនាងខ្ញុំថា មកយកកូនត្រឹមត្រូវ ពេលពួកខ្ញុំទៅយកមកវិញ កែងវត្ត



Scanned by CamScanner

ជេរប្រមាថ គេលើកូននាងខ្ញុំ ហើយនាងខ្ញុំក៏បានដេញឈ្មោះ [redacted] ឲ្យចេញពីផ្ទះរបស់នាងខ្ញុំ ដោយនាងខ្ញុំមិនបានជេរប្រមាថ ឬគំរាមថានឹងបាញ់ឡើងចោលអីនោះទេ ពេលនោះឈ្មោះ [redacted] ក៏បានខឹងនឹងនាងខ្ញុំ តែម្តង ។

ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាន ក្នុងពេលសវនាការ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖

\+ ដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រាប់គ្រាន់ ហើយការឆ្លើយដោះសាររបស់ជនជាប់ចោទគ្មានមូលដ្ឋានអាចយកមកពិចារណាបាន។ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ និងសំណូមពរដល់ចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសកម្មភាពដែលបានប្រព្រឹត្ត។

+មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោ[redacted]ភេទប្រុស អាយុ៨៨ឆ្នាំ ជនជាតិខ្មែរ ជាប់ចោទពីបទៈ គំរាមកំហែង ប្រព្រឹត្តនៅចំណុច ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២១.០៧.២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ ។

+មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ[redacted] ភេទស្រី អាយុ៨៧ឆ្នាំ ជនជាតិខ្មែរ ជាប់ចោទពីបទៈ គំរាមកំហែង ប្រព្រឹត្តនៅចំណុច ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២១.០៧.២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ ។

+សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ០៨ អ.យ/១៨ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ទុកជាបានការទាំងស្រុង និងសូមឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

1) ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
2) ក្រោយពីបានពិនិត្យភស្តុតាង
3) ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាដំបូងខេត្តកោះកុង</u>**

**<u>យល់ឃើញថា</u>**

១. ជនជាប់ចោទឈ្មោ[redacted]ភេទប្រុស អាយុ៨៨ឆ្នាំ ជនជាតិ ខ្មែរ បានឆ្លើយថា៖ កាលពីថ្ងៃមិនចាំ ខែកក្កដា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល១៥ និង៣០នាទីរសៀល ខ្ញុំចេញពីបន្ទប់ទឹកក្នុងផ្ទះស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឃើញប្រពន្ធរបស់ខ្ញុំឈ្មោះ [redacted] បានឈរនៅមុខផ្ទះកំពុងហាមឈ្មោះ [redacted] ត្រូវជាប្អូនថ្លៃ មិនឲ្យចូលក្នុងផ្ទះរបស់ ខ្ញុំបាទ ពេលនោះខ្ញុំក៏បានចេញទៅដេញឈ្មោះ[redacted] មិនឲ្យចូលមកក្នុងផ្ទះរបស់ខ្ញុំបាទទេ ដោយឈ្មោះ [redacted]មានស្ថានភាពស្រវឹងជោគ ដើរគ្រេតគ្រូត ខ្ញុំបាននិយាយថា អញមិនឲ្យ អែងចូលផ្ទះអញទេ បើឯងស្រវឹងជោកចឹង ពេលនោះ ក្មួយស្រីរបស់ខ្ញុំ ឈ្មោះ[redacted]បាន ដើរមកជួបឈ្មោះ[redacted]មួយភ្លែត ដោយឈ្មោះ [redacted]បានឲ្យអ្វីទៅកូនគេនោះខ្ញុំក៏ មិនបានដឹងទេ ពេលដែលជួបកូនគេហើយឈ្មោះ មិន [redacted]បានបណ្តើរកង់ចេញពីផ្ទះរបស់ខ្ញុំ តែម្តងទៅ ។ ខ្ញុំមិនបានគំរាមឈ្មោះ[redacted] ទេគឺ



Scanned by CamScanner

គ្រាន់តែបិនឲ្យឈ្មោះ[redacted]ជាន់ដីផ្ទះ ខ្ញុំ ។ ប្រពន្ធខ្ញុំឈ្មោះ[redacted]បិនបាន ជេរប្រមាថ ឬគំរាមកំហែង អ្វីនោះទេ ។ ខ្ញុំមិនបាន រកបាញ់ឈ្មោះ [redacted]អ្វីនោះទេ ។

២. ជនជាប់ចោទឈ្មោះ[redacted]ភេទស្រី អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា៖ កាលពីថ្ងៃមិនចាំខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១៥ និង០០នាទី ខ្ញុំនិងប្ដី ឈ្មោះ[redacted]បាននៅក្នុងផ្ទះស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ស្រាប់តែឈ្មោះ[redacted]មកទារ យកកូនរបស់គេ ឈ្មោះ[redacted]ដែលមានម្ដាយឈ្មោះ[redacted]ដែលបានដាក់ពាក្យ លែងលះគ្នាជាមួយឈ្មោះ[redacted]តែមិនទាន់ចេញសាលក្រម ហើយពួកគេស្នាក់នៅផ្ទះជា មួយនាងខ្ញុំ និងប្ដី ។ ពេលនោះនាងខ្ញុំថា មកយកកូនត្រឹមត្រូវ ពេលពួកខ្ញុំទៅយកមកវិញ តែងតែ ជេរប្រមាថ មកលើពួកនាងខ្ញុំ ហើយនាងខ្ញុំក៏បានដេញឈ្មោះ[redacted]ឲ្យចេញពីផ្ទះរបស់នាង ខ្ញុំ ដោយនាងខ្ញុំមិនបានជេរប្រមាថ ឬគំរាមថានឹងបាញ់ហ្វែងចោលអីនោះទេ ពេលនោះឈ្មោះ[redacted] ក៏បានខឹងនឹងនាងខ្ញុំ តែម្ដង ។

៣. ពិតជាមានអង្គហេតុដូចបទចោទប្រកាន់កើតឡើងប្រាកដមែន ។

៤. ជនជាប់ចោទអវត្តមានបង្ហាញខ្លួននាពេលសវនាការ ។

៥. ផ្អែកតាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ ។

៦. ផ្អែកតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៧.មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]និងឈ្មោះ[redacted]។

៨.តំណាងអយ្យការបានតម្កល់ការចោទប្រកាន់ ដូចមាននៅក្នុងដីកាសន្និដ្ឋានលេខ ០៨ អ.យ/១៨ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ។

៩. យោងតាមមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ។

<u>**ហេតុដូច្នេះ**</u>

<u>**វិនិច្ឆ័យសេចក្ដី**</u>

**១-ផ្ដន្ទាទោស៖**

ក/.ឈ្មោះ[redacted]ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់០៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន១.០០០.០០០ (មួយលាន)រៀល ។

ជាប់ចោទពី បទគំរាមកំហែង ប្រព្រឹត្តនៅចំណុច ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២១.០៧.២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ ។

ខ/.ឈ្មោះ[redacted] ភេទស្រី អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន១.០០០.០០០ (មួយលាន)រៀល ។

ជាប់ចោទពីបទ គំរាមកំហែង ប្រព្រឹត្តនៅចំណុច ភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២១.០៧.២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ ។



Scanned by CamScanner

២-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កោះកុង ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

ក្រឡាបញ្ជី

[redacted]

បានឃើញ

កោះកុង ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner